**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧០...០១៨...១៩៧...ប្រ.ក

# ប្រកាស
# ស្តីពី
# លក្ខណៈសម្គាល់នៃធនប័ត្រ ប្រភេទ ២០០០០ រៀល គំរូថ្មី

***********

អនុលោមតាមអនុក្រឹត្យលេខ ៦២ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការចេញផ្សាយធនប័ត្រ ប្រភេទ ២០០០០ រៀល គំរូថ្មី ក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា សូមប្រកាសផ្សាយជាសាធារណៈនូវលក្ខណៈសំគាល់នៃធនប័ត្រគំរូថ្មីនេះ មានដូចខាងក្រោម ៖

**ក- លក្ខណៈទូទៅ ៖**

- ទំហំធនប័ត្រ ៖ បណ្តោយ ១៥៥ មម និងទទឹង ៧២ មម
- ពណ៌ចម្បង គឺពណ៌ស៊ីជំពូ ពណ៌ផ្កាឈូក និងពណ៌ត្នោត ។

**ខ- ផ្ទៃខាងមុខនៃធនប័ត្រ ៖**

**- ផ្នែកកណ្តាល** ខាងស្តាំត្រូវបានរំលេចឡើងនូវព្រះឆាយាលក្ខណ៍សំឡឹងចុះក្រោមនៃ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** មើលពីមុខបញ្ឆិតចំហៀងខាងឆ្វេង និងមានរូបក្បាច់ចម្លាក់ប្រាសាទបន្ទាយស្រីនៅពីក្រោយនិងពីក្រោមខាងឆ្វេងមានលេខ "២០០០០" នៅពីលើគេ បន្ទាប់មកគឺជាហត្ថលេខារបស់ទេសាភិបាលនិងអគ្គបេឡា ព្រមទាំងរូបចម្លាក់ហោជាងនៅប្រាសាទបន្ទាយស្រី និងនៅពីក្រោមនោះមានលេខ-មាលាបោះពុម្ពដោយទឹកខ្មៅពណ៌ខ្មៅ រូបចម្លាក់នាគក្បាល ៥ នៅប្រាសាទបន្ទាយស្រី និងអក្សរ " ពីរម៉ឺនរៀល " ព្រមទាំងអក្សរ " អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់ " នៅគែមខាងក្រោមនោះ ។

**- ផ្នែកខាងស្តាំ** ជ្រុងលើមានអក្សរ " ធនាគារជាតិនៃកម្ពុជា " ជ្រុងក្រោមមានលេខ-មាលាបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហម ព្រមទាំងលេខ " ២០០០០ " និងលេខ " 20000 " នៅបន្តបន្ទាប់គ្នាពីក្រោមនោះ និងនៅគែមក្រដាសប្រាក់មានរូបភាពអង្គជ៉ៅចំណាំត្រូវបានបោះពុម្ពតាមបន្ទាត់បញ្ឈរ ដែលនឹងចេញជាលេខ " 20000 " ពេលមើលឆ្លុះទៅរកប្រភពពន្លឺអ្វីមួយ ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- **ផ្នែកខាងឆ្វេង** មានលេខ "20000" ព្រាលៗបោះពុម្ពតាមបន្ទាត់បញ្ឈរព្រមទាំងមាននិមិត្តសញ្ញាពិសេសសម្រាប់ជនពិការភ្នែកនៅពីក្រោមនោះ និងនៅកៀនខាងឆ្វេងមានបន្ទះហូឡូក្រាមទំហំ ១០មម ប្រកបដោយបច្ចេកវិទ្យាទំនើបនិងស្តង់ដារកម្រិតខ្ពស់កាត់ទទឹងក្រដាសប្រាក់ពីលើដល់ក្រោម ។

**គ- ផ្ទៃខាងខ្នង ៖**

- **ផ្នែកកណ្តាល** ត្រូវបានរំលេចឡើងនូវរូបភាពប្រាសាទបន្ទាយស្រីក្នុងខេត្តសៀមរាប និងមានអក្សរ " ពីរម៉ឺនរៀល " នៅពីក្រោម ។

- **ផ្នែកខាងស្តាំ** ជារូបចម្លាក់ថ្មនរសីង្ហនៅប្រាសាទបន្ទាយស្រី និងមានលេខ "២០០០០" នៅពីក្រោមនោះ ព្រមជាមួយលេខ "20000" ដែលត្រូវបានបោះពុម្ពតាមបន្ទាត់បញ្ឈរនៅជ្រុងខាងលើនៃគែមក្រដាសប្រាក់ ។

- **ផ្នែកខាងឆ្វេង** ជ្រុងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" និងអក្សរ " NATIONAL BANK OF CAMBODIA " ជ្រុងក្រោមមានលេខ " 2017 " និងលេខ " ២០០០០ " និងនៅគែមក្រដាសប្រាក់មានរូបភាពអង្គដៅចំណាំត្រូវបានបោះពុម្ពតាមបន្ទាត់បញ្ឈរ ដែលត្រួតស៊ីគ្នាជាមួយនឹងរូបភាពអង្គដៅចំណាំនៅផ្ទៃខាងមុខនៃធនប័ត្រ ។

ចាប់ពីថ្ងៃចេញប្រកាសនេះតទៅ ធនប័ត្រប្រភេទ ២០០០០ រៀល គំរូថ្មី ត្រូវបានដាក់ឲ្យធ្វើចរាចរទន្ទឹមគ្នាជាមួយនឹងធនប័ត្រជាតិប្រភេទផ្សេងៗទៀតដែលត្រូវបានចេញផ្សាយរួចមកហើយ។ សាធារណជនគ្រប់រូបត្រូវពិនិត្យ-សម្គាល់ធនប័ត្រគំរូថ្មីនេះឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការភ័ន្តច្រឡំ ។

ថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨

**ទេសាភិបាល**

**ជា.ចាន់តូ**